២០១៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ២៧០២ MIH / 2016

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦

**សូមជម្រាបមក**
**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី**
**ជាម្ចាស់ផ្ទះជួលបន្ទប់**

**កម្មវត្ថុ** ៖ សំណើសុំចូលរួមចំណែកលើកស្ទួយជីវភាពកម្មករ-កម្មការិនី តាមរយៈការកាត់បន្ថយការចំណាយថ្លៃទឹកស្អាត ដល់កម្មករ-កម្មការិនី ជួលបន្ទប់។

**យោង** ៖ សេចក្តីអំពាវនាវរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃច័ន្ទទី០៥ ខែធ្នូ ឆ្នាំ២០១៦ ក្នុងពិធីសម្ពោធរោងចក្ររបស់ក្រុមហ៊ុនកូកា-កូឡាថ្មី ក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី** ដែលជាម្ចាស់ផ្ទះជួលបន្ទប់ មេត្តាជ្រាបថា ៖ ជាការឆ្លើយតបចំពោះការអំពាវនាវកន្លងទៅរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីចូលរួមចំណែកលើកស្ទួយជីវភាពកម្មករ-កម្មការិនី តាមរយៈការកាត់បន្ថយចំណាយថ្លៃទឹកស្អាតដល់អ្នកជួលបន្ទប់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក៏ដូចជាអាជ្ញាធរមូលដ្ឋាន បានខិតខំប្រឹងប្រែងចុះជួបផ្ទាល់ដល់ទីកន្លែង និងតភ្ជាប់បណ្តាញទឹកស្អាតជូន **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី** ដែលជាម្ចាស់ផ្ទះជួលបន្ទប់ និងបានឯកភាពបន្ទូរបន្ថយតម្លៃលក់ទឹកមកជាតម្លៃថេរត្រឹម ១.០៣០រៀលក្នុងមួយម៉ែត្រគូប ក្នុងគោលបំណងដើម្បី **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី** លក់ចែកជូនបន្តទៅឲ្យកម្មករ-កម្មការិនី សិស្ស-និស្សិត ដែលជាអ្នកជួលបន្ទប់ ក្នុងតម្លៃអនុគ្រោះពី១.១០០ ទៅ១.២០០ រៀលក្នុងមួយម៉ែត្រគូប។ រហូតមកដល់ពេលបច្ចុប្បន្ននេះ មានផ្ទះជួលចំនួន ៥.៣៤៣ (១១៥.៦៦៨ បន្ទប់) បានសហការ និងកំពុងអនុវត្តតម្លៃអនុគ្រោះ។ ជាសំណូមពរ សូម **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី** មេត្តារក្សាការលក់ចែកបន្ត ក្នុងតម្លៃអនុគ្រោះដូចដែលបានឯកភាពគ្នា។

ជាជំហានបន្ត ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ រួមទាំងអាជ្ញាធរមូលដ្ឋាន កំពុងបន្តស្រាវជ្រាវស្រង់ស្ថិតិផ្ទះជួលផ្សេងៗទៀត ដែលអាចមានក្នុងតំបន់ជាយក្រុង និងចុះអនុវត្តតាមគោលការណ៍ដែលបានអនុវត្តកន្លងមក ដើម្បីឆ្លើយតបជាបន្តទៀតចំពោះសេចក្តីអំពាវនាវ

ថ្មីៗ នេះ របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** កាលពីថ្ងៃច័ន្ទទី០៥ ខែធ្នូ ឆ្នាំ២០១៦ ក្នុងពិធីសម្ពោធរោងចក្ររបស់ក្រុមហ៊ុនកូកា-កូឡាថ្មី ក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។ ដោយហេតុនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមធ្វើការអំពាវនាវស្នើសុំ **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី** ដែលជាម្ចាស់ផ្ទះជួលបន្ទប់ ដែលមិនទាន់បន្ធូរបន្ថយតម្លៃលក់ទឹក សូមមេត្តាចូលរួមសហការលើការងារនេះ ក្នុងគោលបំណងចូលរួមចំណែកលើកស្ទួយជីវភាពកម្មករ-កម្មការិនី តាមរយៈការកាត់បន្ថយការចំណាយថ្លៃទឹកស្អាត ដល់កម្មករ-កម្មការិនីជួលបន្ទប់។ ក្រសួងក៏សូមបញ្ជាក់បន្ថែមទៀតថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** រាជរដ្ឋាភិបាល ក៏នឹងដំឡើងប្រាក់បៀវត្សអប្បបរមា ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ នេះតទៅ ជូនកម្មករ-កម្មការិនីទាំងអស់ក្នុងគោលបំណងលើកស្ទួយជីវភាពរបស់ពួកគាត់។

សេចក្តីដូចបានជម្រាបជូនខាងលើ ក្នុងនាមក្រសួងឧស្សាហកម្ម និងសិប្បកម្ម ខ្ញុំសូមអំពាវនាវដល់ **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី** ដែលជាម្ចាស់ផ្ទះជួលបន្ទប់ សូមមេត្តាចូលរួមសហការគ្នា ដោយកុំប្រើប្រាស់ឱកាសខាងលើ ដើម្បីដំឡើងថ្លៃឈ្នួលបន្ទប់បន្ថែមទៀត។ សូម **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី** មេត្តាចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការលើកស្ទួយជីវភាពរបស់កម្មករ-កម្មការិនីយើង។

សូម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី មេត្តាទទួលនូវការរាប់អានដោយស្មោះអំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន ៖**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

  *«ដើម្បីជូនជ្រាបជាព័ត៌មាន»*
- សាលារាជធានីភ្នំពេញ
- គ្រប់សាលាខណ្ឌទូទាំងរាជធានីភ្នំពេញ

  *«ដើម្បីជូនជ្រាប និងជួយផ្សព្វផ្សាយ»*
- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

  *«ដើម្បីជ្រាប និងអនុវត្ត»*
- ឯកសារ-កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com